**NEWS RELEASE**

UNITED NATIONS HUMAN RIGHTS SPECIAL PROCEDURES
SPECIAL RAPPORTEURS, INDEPENDENT EXPERTS & WORKING GROUPS

# អ្នកជំនាញ អ.ស.ប អំពាវនាវឲ្យបើកកិច្ចសន្ទនាផ្នែកនយោបាយ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងសន្តិភាព

ទីក្រុងហ្សឺណែវ (ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៩) – អ្នកជំនាញសិទ្ធិមនុស្សអង្គការសហប្រជាជាតិបានជំរុញប្រជាជនកម្ពុជាឲ្យផ្លាស់ប្តូរវប្បធម៌នយោបាយទៅជាកិច្ចសន្ទនាមួយ ដែលផ្តោតទៅលើបញ្ហាជាជាងផ្តោតលើបុគ្គល ដែលវិធីមួយដែលឈានទៅមុខ និងបង្កើតមូលដ្ឋានរឹងមាំសម្រាប់សន្តិភាពយូរអង្វែង ការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងសម្រេចបានសិទ្ធិមនុស្សទាំងអស់។

នៅក្នុងដំណើរទស្សនកិច្ចលើកទីប្រាំពីរ របស់លោកស្រីមកកាន់ប្រទេសកម្ពុជា អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា លោកស្រី រ៉ូណា ស្មីត បានបន្តពិនិត្យអំពីស្ថានភាពសិទ្ធិមនុស្សទូទៅ និងការអនុម័តទទួលយករបស់ប្រទេសកម្ពុជានូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ (SDGs)។

អ្នករាយការណ៍ពិសេសត្រូវបានលើកទឹកចិត្តតាមរយៈវិធានការផ្សេងៗ ដែលបានធ្វើឡើងចាប់តាំងពីទស្សនកិច្ចចុងក្រោយរបស់លោកស្រីក្នុងខែវិច្ឆិកា រួមទាំងការចាប់ផ្តើមដំណើរការ ធ្វើវិសោធនកម្មច្បាប់សហជីព និងការត្រៀមខ្លួនដើម្បីពិនិត្យច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ការដកចេញលក្ខខណ្ឌតម្រូវលើអង្គការសង្គមស៊ីវិល ឲ្យជូនដំណឹងបីថ្ងៃដល់អាជ្ញាធរមុនពេលធ្វើសកម្មភាព និងការរៀបចំវេទិកាភាពជាដៃគូជាតិលើកទីពីរ ជាមួយអង្គការសង្គមស៊ីវិលក្នុងខែមករា។

លោកស្រី ស្មីត បានមានប្រសាសន៍នៅក្នុងសេចក្តីថ្លែងការណ៍បញ្ចប់ទស្សនកិច្ចរបស់លោកស្រីថា "វេទិកាថ្នាក់ជាតិផ្តល់នូវមធ្យោបាយមួយសម្រាប់កិច្ចសន្ទនារវាងអង្គការសង្គមស៊ីវិលនានា និងរដ្ឋាភិបាល ហើយខ្ញុំសង្ឃឹមថា ការសន្ទនាបែបនេះ អាចក្នុងន័យស្ថាបនា និងកសាងទំនុកចិត្ត" ។

ទោះយ៉ាងណាក៏ដោយ នៅក្នុងវិស័យសិទ្ធិនយោបាយ អ្នករាយការណ៍ពិសេសបានឃើញការរីកចម្រើនជាក់ស្តែងមានតិចតួចប៉ុណ្ណោះ។ លោកស្រី ស្មីត បានកត់សម្គាល់អំពីវិធានការរបស់នគរបាល ឬតុលាការប្រឆាំងនឹងអតីតសមាជិក និងមន្ត្រីជាប់ឆ្នោតរបស់គណៈបក្សសង្គ្រោះជាតិចំនួន ៨០ រូប ដែលលោកស្រីបានកត់សម្គាល់ថា មិនសំដៅឲ្យមានការពង្រឹងសិទ្ធិនយោបាយ និងលំហប្រជាធិបតេយ្យឡើយ។

"វប្បធម៌នយោបាយថ្មីមួយ ត្រូវមានជាចាំបាច់នៅប្រទេសកម្ពុជា"។ វប្បធម៌មួយដែលផ្តោតលើបញ្ហាដែលជាកង្វល់សម្រាប់ប្រទេសកម្ពុជា និងប្រជាជនកម្ពុជាជាជាងបុគ្គល"។ អ្នករាយការណ៍ពិសេសបានមាន

ប្រសាសន៍បន្តទៀតថា "វប្បធម៌គួរផ្អែកលើការគោរពសម្រាប់ការជជែកដេញដោលដោយចំហ និងក្នុងន័យស្ថាបនា ពាក់ព័ន្ធនិងសំឡេងភាគច្រើន និងការបញ្ចេញដោយសេរីនូវមតិផ្សេងៗ រាប់ទាំងមតិផ្ទុយគ្នាផងដែរ។

លោកស្រី ស្មីត បានអំពាវនាវជាថ្មីម្តងទៀត ឲ្យដោះលែងលោក កឹម សុខា មេដឹកនាំអតីតគណបក្សសង្គ្រោះជាតិដែលត្រូវបានរំលាយ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៧ ពីការឃុំខ្លួន និងពីការឃុំខ្លួនដោយមានលក្ខខណ្ឌ និងពន្លឿនការបិទការស៊ើបសួរលើសំណុំរឿងរបស់គាត់ ឬទំលាក់ចោលការចោទប្រកាន់នានា។

ក្នុងអំឡុងពេលបំពេញបេសកកម្មនេះ អ្នករាយការណ៍ពិសេស បានទាញការយកចិត្តទុកដាក់ចំពោះគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ ដែលផ្តល់ជាមគ្គុទ្ទេសក៍ ដើម្បីសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព ក្នុងវិធីដែលគោរពសិទ្ធិមនុស្ស។ លោកស្រីបានស្វាគមន៍ចំពោះការអនុម័តកាលពីពេលថ្មីៗនេះនូវផែនការយុទ្ធសាស្រ្តមូលដ្ឋានីយកម្មនៃគោលដៅការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងបានលើកទឹកចិត្តដល់វិធីនានា ដើម្បីពង្រឹងសិទ្ធិមនុស្ស។

លោកស្រី ស្មីត បានមានប្រសាសន៍ថា "ការយកចិត្តទុកដាក់ខ្លាំងលើគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ១៦ (SDG 16) នឹងបង្កើនមហិច្ឆតារបស់កម្ពុជាក្នុងការទទួលបានយុត្តិធម៌សម្រាប់ទាំងអស់គ្នាបញ្ឈប់អំពើហឹង្សា ប្រឆាំងនឹងអំពើពុករលួយ ពង្រឹងនីតិរដ្ឋ ធានានូវការធ្វើសេចក្តីសម្រេចដោយមានការចូលរួម និងការទទួលបានព័ត៌មាន ការការពារសេរីភាពជាមូលដ្ឋាន និងការប្រឆាំងការរើសអើង"។ "ការដាក់បញ្ចូលចំណុចដៅទាំងនេះអាចត្រឹមតែពង្រឹងការអភិវឌ្ឍរបស់កម្ពុជាប៉ុណ្ណោះ ហើយនឹងត្រូវស្របទៅនឹងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី ៤ របស់រដ្ឋាភិបាល"។

អ្នករាយការណ៍ពិសេសក៏បានគូសបញ្ជាក់ផងដែរពីសារៈសំខាន់នៃការមិនទុកឱ្យនរណាម្នាក់ចោល ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីអនុវត្ត គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជា។ លោកស្រីបានលើកទឹកចិត្តដល់រាជរដ្ឋាភិបាលឱ្យទទួលយកការយល់ដឹងទូលំទូលាយថាតើនរណាអាចមានហានិភ័យនៃការទុកចោល ដើម្បីធានាថាកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍត្រូវបានកំណត់ចំណុចដៅ ដែលជាកន្លែងដែលពួកគេត្រូវការបំផុត។

"ជនក្រីក្រ និងជនជិតក្រីក្រចាំបាច់ត្រូវនាំមកពីក្រោយ។ ទោះយ៉ាងណាក៏ដោយ នៅក្នុង និងលើសពីជំពូកនេះមានបុគ្គល និងក្រុមដទៃទៀត ដែលរស់នៅក្នុងស្ថានភាពងាយរងគ្រោះ រួមមានស្រ្តី និងកុមារ ជនពិការសហគមន៍ជនជាតិដើមភាគតិច ឬប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅពីដីធ្លីរបស់ខ្លួន"។ លោកស្រី ស្មីត សង្ឃឹមថា ការធ្វើជំរឿនកាលពីពេលថ្មីៗនេះ និងការស្ទង់មតិសុខភាពប្រជាសាស្រ្តនាពេលខាងមុខនេះ នឹងផ្តល់ទិន្នន័យដ៏មានប្រយោជន៍ ដើម្បីកំណត់អត្តសញ្ញាណអ្នកដែលប្រឈមនឹងហានិភ័យខ្ពស់បំផុត។

លោកស្រី ស្មីត ក៏បានអំពាវនាវផងដែរឲ្យមានការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន ស្តីពីគោលការណ៍លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ដែលជំរុញឲ្យមានការរីកចម្រើន និងភាពរុងរឿងសម្រាប់ទាំងអស់គ្នា ដោយផ្អែកលើកិច្ចសន្ទនាគ្នាដោយបើកចំហ និងមិនទុកនរណាម្នាក់ចោល។ លោកស្រី បានបញ្ជាក់សារជាថ្មី នូវការប្តេជ្ញា

ចិត្តរបស់លោកស្រី ក្នុងការស្តាប់ភាគីពាក់ព័ន្ធទាំងអស់ ដោយមិនលំអៀង និងគាំទ្រកិច្ចសន្ទនាដែលមានលក្ខណៈបរិយាប័ន្ន ទន្ទឹមនឹងពេលដែលលោកស្រីបន្តតាមដាន និងធ្វើការតស៊ូមតិ ដើម្បីទទួលបានសិទ្ធិមនុស្សសម្រាប់ប្រជាជនកម្ពុជាទាំងអស់។

## ចប់

***សាស្ត្រាចារ្យ រ៉ូណា ស្មីត*** *(ចក្រភពអង់គ្លេស) ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងជាអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងខែមីនា ឆ្នាំ២០១៥ ។*

*អ្នករាយការណ៍ពិសេស ពួកគាត់គឺជាផ្នែកមួយនៃអ្វីដែលគេស្គាល់ថាជានីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីពិសេស (ស្ថាប័នដ៏ធំបំផុតមួយនៃអ្នកជំនាញឯករាជ្យនៅក្នុងប្រព័ន្ធសិទ្ធិមនុស្ស អ.ស.ប) គឺជាឈ្មោះទូទៅមួយនៃយន្តការឃ្លាំមើល និងស្វែងរកការពិតឯករាជ្យរបស់ក្រុមប្រឹក្សានេះ។ អ្នកកាន់អាណត្តិនីតិវិធីពិសេស គឺជាអ្នកជំនាញឯករាជ្យ ដែលក្រុមប្រឹក្សាសិទ្ធិមនុស្សបានតែងតាំងឡើង ដើម្បីធ្វើការងារពាក់ព័ន្ធនឹងស្ថានភាពសិទ្ធិមនុស្សរបស់ប្រទេសមួយជាក់លាក់ ឬបញ្ហាសិទ្ធិមនុស្សតាមវិស័យនីមួយៗ នៅគ្រប់តំបន់ទាំងអស់នៃពិភពលោក។ ពួកគាត់មិនមែនជាបុគ្គលិក អ.ស.ប ទេ ហើយធ្វើការឯករាជ្យពីរដ្ឋាភិបាល និង អ.ស.ប។ ពួកគាត់បំរើការក្នុងសមត្ថភាពបុគ្គលផ្ទាល់របស់ខ្លួន ហើយមិនទទួលប្រាក់បៀវត្សរ៍លើការងារនេះឡើយ។*

*ពិនិត្យមើលរបាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីប្រទេសកម្ពុជា និង មើលទំព័រហ្វេសប៊ុករបស់អ្នករាយការណ៍ពិសេស៖ https://www.facebook.com/SpecialRapporteurCambodia/?modal=admin_todo_tour*
*សិទ្ធិមនុស្ស អ.ស.ប គេហទំព័រសម្រាប់ប្រទេស៖ កម្ពុជា*

*សម្រាប់ព័ត៌មានបន្ថែម និងការសាកសួរព័ត៌មានផ្សេងៗ សូមទាក់ទង៖*
*លោកស្រី អ៊ីស្ទឺរ ឡាំ (Esther Lam) តាមរយៈទូរស័ព្ទលេខ៖ (+៤១ ២២ ៩២៨ ៩១ ០៨ ឬ អ៊ីម៉ែល elam@ohchr.org ម៉ាសម៉ូដ ហ្គារហ្គា តាមរយៈទូរស័ព្ទ៖ (+៨៥៥ (០)១២ ៧៩០ ១៧៨ អ៊ីម៉ែល mgarga@ohchr.org )*

*សម្រាប់**ការសាកសួរព័ត៌មាន**ពាក់ព័ន្ធនឹងអ្នកជំនាញឯករាជ្យដទៃទៀតរបស់ អ.ស.ប សូមទាក់ទង៖*
*លោក ហ្សេរ៉ឺមី ឡូរេង់ស៍ (Jeremy Laurence) សិទ្ធិមនុស្ស អ.ស.ប– អង្គភាពប្រព័ន្ធផ្សព្វផ្សាយ តាមរយៈទូរស័ព្ទលេខ៖ (+៤១ ២២ ៩១៧ ៩៣៨៣ ឬ អ៊ីម៉ែល jlaurence@ohchr.org)*